# បន្ទប់សុខភាពនៅតាមសាលារៀន

## ទិវាជាតិសុខភាពមាតា ទារក និងកុមារ
## និងទិវាសុខភាពពិភពលោក

សណ្ឋាគារហៃយ៉ាត់ រីជិនស៊ី រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៥

វេជ្ជបណ្ឌិត **យង់ គន្ធារិទ្ធ**
អនុប្រធានលេខាធិការដ្ឋានគ.អ.ស.ស និងជាអនុប្រធាននាយកដ្ឋានសុខភាពសិក្សា

# មាតិកា

ក. ស្ថិតិអប់រំនៅកម្ពុជា
ខ. ទិន្នន័យបន្ទប់សុខភាពតាមសាលារៀនសាធារណៈ
គ. គោលការណ៍ប្រតិបត្តិស្តង់ដាអប្បបរមាស្តីពីបន្ទប់សុខភាព
ឃ. បញ្ហាប្រឈមនិងដំណោះស្រាយ

# ក. ស្ថិតិអប់រំនៅកម្ពុជា

| គ្រឹះស្ថានសិក្សា | គ្រឹះស្ថានសិក្សាសាធារណៈ | | | គ្រឹះស្ថានសិក្សាឯកជន | | |
|---|---|---|---|---|---|---|
| | ចំនួនសាលា | សិស្សសរុប | សិស្សស្រី | ចំនួនសាលា | សិស្សសរុប | សិស្សស្រី |
| មត្តេយ្យសិក្សាសហគមន៍ | 3,290 | 81,767 | 42,249 | | | |
| មត្តេយ្យសិក្សា | **4,694*** | 257,725 | 128,964 | 907 | 61,467 | 29,974 |
| បឋមសិក្សា | 7,341* | 2,265,783 | 1,086,892 | 854 | 173,466 | 84,125 |
| អនុវិទ្យាល័យ | 1,244* | 333,248 | 174,895 | 99 | 4,916 | 2,544 |
| វិទ្យាល័យ | 581* | 724,864 | 389,547 | 316 | 78,877 | 40,559 |
| **សរុប** | **17,150** | **3,663,369** | **1,822,547** | **2,065** | **318,726** | **157,202** |
| គ្រឹះស្ថានឧត្តមសិក្សា | **79** | | | **110** | | |
| និស្សិតឧត្តមសិក្សា | និស្សិតសរុប | | | និស្សិតស្រីសរុប (៥២.៣%) | | |
| | 284,599 | | | 148,757 | | |

* មត្តេយ្យសិក្សាដាច់ដោយឡែក = 380, មត្តេយ្យសិក្សាក្នុងបឋមសិក្សា = 4,334 (Source: EMIS SY 2024-2025)

# ទិន្នន័យបន្ទប់សុខភាពតាមសាលារៀនសាធារណៈ

| គ្រឹះស្ថានសិក្សា | ចំនួនសរុប | បន្ទប់សុខភាព ដាច់ដោយឡែក | ជ្រុងណាមួយ ធ្វើជាបន្ទប់សុខភាព | សរុប | % |
|---|---|---|---|---|---|
| មត្តេយ្យសិក្សា ដាច់ដោយឡែក | **380** | 37 | 133 | 170 | 44.7 |
| បឋមសិក្សា | 7,341 | 422 | 1,981 | 2,403 | 32.7 |
| អនុវិទ្យាល័យ | 1,244 | 140 | 423 | 563 | 45.3 |
| វិទ្យាល័យ | 581 | 185 | 220 | 405 | 69.7 |
| **សរុប** | **9,546** | **784** | **2,757** | **3,541** | **37.1** |

**ដៃគូសហការ : MoH, UNFPA, WFP, WHO, RHAC, ADRA Cambodia, Odong House, Kagawa University of Japan, Tokyo Gakugei University of Japan, Nippon Foundation, PSE, FIDR, Fred Hollows Foundation, Communities,... and Government Budget.**

# គោលការណ៍ប្រតិបត្តិស្តង់ដាអប្បបរមាស្តីពីបន្ទប់សុខភាព




## បុព្វកថា

**បន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សា** ជាយន្តការដ៏មានសារសំខាន់នៅនឹងកន្លែងដើម្បីផ្តល់សេវាសង្គ្រោះបឋម សេវាប្រឹក្សាសុខភាពបឋមផ្សេងៗដល់អ្នកសិក្សានិងបុគ្គលិកអប់រំមុននឹងបញ្ជូនទៅរកសេវាថែទាំ ព្យាបាលតាមជំនាញឯកទេស ហើយបន្ទប់សុខភាពក៏ជាទីកន្លែងសម្រាប់ផ្តល់ព័ត៌មានពីសុខភាព និងការអប់រំសុខភាពផងដែរ។ បន្ទប់សុខភាពដំណើរការបំពេញមុខងារពេញលេញនឹងចូលរួមអនុវត្តនូវអាទិភាពគន្លឹះ "ការលើកកម្ពស់សុខភាពសិក្សា ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្សតាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន" ដែលរាជរដ្ឋាភិបាលអាណត្តិទី៧នៃរដ្ឋសភា បានកំណត់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ថាជាអាទិភាពគន្លឹះមួយក្នុងចំណោមអាទិភាពស្នូលគន្លឹះទាំងបួន ដើម្បីពង្រឹងគុណភាពអប់រំសម្រាប់ចំណេះទូទៅចាប់ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាទុតិយភូមិ។

ឯកសារ **"គោលការណ៍ប្រតិបត្តិស្តង់ដាអប្បបរមាស្តីពីបន្ទប់សុខភាព"** នេះ ជាសមិទ្ធផលថ្មីមួយបន្ថែមទៀតបង្កើតឡើងក្រោមកិច្ចសហការរវាងក្រសួងអប់រំ យុវជន និងកីឡាជាមួយអង្គការមណ្ឌល គាំទ្រការអប់រំ (ESC KIZUNA) សាកលវិទ្យាល័យ តូក្យូ ហ្គាគីហ្គេ (Tokyo Gakugei University) ប្រទេសជប៉ុន តាមរយៈមូលនិធិនីបប៉ុន (The Nippon Foundation) ក្នុងគោលបំណងឱ្យមុខងារបន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សាសាធារណៈទាំងអស់ មានស្តង់ដាអប្បបរមាសម្រាប់ប្រតិបត្តិ និងមានដំណើរការដោយរលូនស្របតាមមុខងាររបស់ខ្លួន។

បន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សាដំណើរការទៅបាន ចាំបាច់ត្រូវមានការចូលរួមពីគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា គ្រូបង្រៀន សិស្សានុសិស្ស អ្នកអាណាព្យាបាល អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ និងវិស័យឯកជន ក្នុងការបំពាក់សម្ភារៈបរិក្ខារ ការពង្រឹងសមត្ថភាពទាំងការដឹកនាំគ្រប់គ្រងនិងការងារប្រតិបត្តិ យន្តការទំនាក់ទំនង និងត្រូវមានការប្តេជ្ញាចិត្តរបស់អ្នកបំពេញការងារប្រចាំថ្ងៃផងដែរ។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា **"គោលការណ៍ប្រតិបត្តិស្តង់ដាអប្បបរមាស្តីពីបន្ទប់សុខភាព"** នេះ ក្លាយជាឧបករណ៍ជំនួយស្មារតីសម្រាប់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈនិងគ្រូទទួលបន្ទុកការងារសុខភាពសិក្សា ក្នុងការអភិវឌ្ឍនិងដំណើរការបន្ទប់សុខភាពប្រកបដោយប្រសិទ្ធភាព។

ថ្ងៃសុក្រ ១២ រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

1) មុខងារ
2) លក្ខណៈមូលដ្ឋាន
3) រចនាសម្ព័ន្ធគ្រប់គ្រង
4) ថវិកាប្រតិបត្តិ
5) ដំណើរការប្រតិបត្តិ
6) សម្ភារៈបរិក្ខារ
7) ការសង្គ្រោះបឋម
8) របៀបពិនិត្យកាយសម្បទា
9) ឯកសារសម្រាប់ប្រើប្រាស់
10) ឯកសារឌីជីថលសម្រាប់ប្រើប្រាស់
11) ការវាយតម្លៃដំណើរការប្រតិបត្តិ

# ១- មុខងាររបស់បន្ទប់សុខភាព

**មុខងារ**បន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សា ជាកន្លែងសម្រាប់អ្នកសិក្សានិងបុគ្គលិកអប់រំមកទទួលសេវាសុខភាពបឋម សេវាប្រឹក្សាបឋម មុននឹងបញ្ជូនទៅរកសេវាថែទាំ ព្យាបាល ឬសេវាសុខភាពចាំបាច់ដទៃផ្សេងទៀត។

- ផ្តល់សេវាសង្គ្រោះបឋមដល់អ្នកមានបញ្ហាសុខភាព កាត់បន្ថយការឈឺចាប់ និងហានិភ័យធ្ងន់ធ្ងរចំពោះសុខភាពដែលបានកើតឡើងក្នុងគ្រឹះស្ថានសិក្សា មុននឹងបញ្ជូនទៅរកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យ ព្រមទាំងជាកន្លែងផ្តល់ការប្រឹក្សាសុខភាព ផ្លូវកាយ ផ្លូវចិត្ត សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ព្រមទាំងសកម្មភាពសុខភាពសិក្សាដូចជា ការពិនិត្យសុខភាពនិងកាយសម្បទា ការអប់រំសុខភាព និងការផ្តល់ថ្នាំបង្ការជាដើម។
- ផ្សារភ្ជាប់ទំនាក់ទំនងរវាងគ្រឹះស្ថានសិក្សា សហគមន៍ និងមណ្ឌលសុខភាព ឬមន្ទីរពេទ្យពាក់ព័ន្ធទៅនឹងសកម្មភាពសុខភាពសិក្សា។

# ២- លក្ខណៈមូលដ្ឋានរបស់បន្ទប់សុខភាព

លក្ខណៈមូលដ្ឋានរបស់បន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សា៖

- មានទីតាំងនៅបន្ទប់ជាន់ផ្ទាល់ដី អាចជាប់ឬក្បែរបន្ទប់ទីចាត់ការ ងាយស្រួលសម្រាប់យានជំនិះចូលដល់ ហើយសិស្ស គ្រូ ឬអ្នកអាណាព្យាបាលសិស្សងាយស្រួលមើលឃើញ និងអាចចេញចូលបានគ្រប់ពេលម៉ោងសិក្សា។
- មានបំពាក់សម្ភារៈបរិក្ខារប្រើប្រាស់ចាំបាច់មួយចំនួន មានអ្នកទទួលខុសត្រូវប្រចាំការគ្រប់ម៉ោងសិក្សា ព្រមទាំងមានផ្សព្វផ្សាយពីព័ត៌មានពីសុខភាពសិក្សា។
- ករណីមិនអាចមានបន្ទប់ដាច់ដោយឡែក ត្រូវបង្កើតជាទីតាំងសមល្មមនៅក្នុងបន្ទប់ទីចាត់ការ ការិយាល័យគណៈគ្រប់គ្រង ឬបណ្ណាល័យជាដើម ដោយគ្រាន់តែបំពាក់សម្ភារៈបរិក្ខារតាមធនធានរបស់គ្រឹះស្ថានសិក្សា។

# ៣- រចនាសម្ព័ន្ធគ្រប់គ្រងរបស់បន្ទប់សុខភាព



# ៤- ថវិកាប្រតិបត្តិបន្ទប់សុខភាព

- គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សានិងគណៈកម្មការទទួលបន្ទុកបន្ទប់សុខភាពត្រូវដាក់សំណើចំណាយថវិកាដំណើរការបន្ទប់សុខភាពទៅក្នុងផ្នែកនៃកញ្ចប់ចំណាយប្រតិបត្តិរបស់គ្រឹះស្ថានសិក្សា ដើម្បីធានាថាបន្ទប់សុខភាពមានដំណើរការដោយរលូនពេញមួយឆ្នាំសិក្សា។
- ក្នុងករណីដែលថវិកាដំណើរការប្រតិបត្តិការបន្ទប់សុខភាពមិនគ្រប់គ្រាន់ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សានិងគណៈកម្មការទទួលបន្ទុកបន្ទប់សុខភាព អាចបង្កើតជាប្រព័ន្ធឬសកម្មភាពណាមួយ ដើម្បីទទួលបានកិច្ចសហប្រតិបត្តិការពីសហគមន៍តាមរយៈគណៈកម្មាធិការសុខភាពសិក្សា។
- គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាឬគណៈកម្មការទទួលបន្ទុកបន្ទប់សុខភាព ត្រូវចាត់ចែងបំពាក់បន្ថែមនូវសម្ភារៈបរិក្ខារសង្គ្រោះបឋមឬសម្ភារៈបរិក្ខារចាំបាច់ទាំងឡាយណាដែលប្រើអស់សម្រាប់ធានាឱ្យបន្ទប់សុខភាពមានដំណើរការពេញមួយឆ្នាំសិក្សា។

# ៥- ដំណើរការប្រតិបត្តិបន្ទប់សុខភាព

1. ការសង្គ្រោះបឋម
2. ការពិនិត្យកាយសម្បទា
3. ការសហការផ្តល់ថ្នាំបង្ការ
4. ការប្រឹក្សាផ្លូវចិត្ត
5. ការគ្រប់គ្រងនិងតាមដានព័ត៌មានសុខភាពសិស្ស
6. ការអប់រំសុខភាព ( ផ្ទាល់ មិនផ្ទាល់ ... )
7. ការចូលរួមអភិវឌ្ឍសោភណភាពនិងសួនបៃតងតាមសាលារៀន
8. សកម្មភាពសុខភាពជាមួយសហគមន៍
9. យន្តការទំនាក់ទំនងជាមួយគណៈកម្មការសុខភាពសិក្សា




Android App

ios App

# ៦- សម្ភារៈបរិក្ខារនៅបន្ទប់សុខភាព



1. សម្ភារៈបិរក្ខារទូទៅ
2. សម្ភារៈបរិក្ខារសម្រាប់ការពិនិត្យកាយសម្បទា
3. សម្ភារៈបិរក្ខារសម្រាប់ការអប់រំសុខភាពនិងការប្រឹក្សាសុខភាព
4. សម្ភារៈបរិក្ខារសម្រាប់ការសង្គ្រោះបឋម
5. សម្ភារៈអនាម័យ

# ៦- សម្ភារៈបរិក្ខារនៅបន្ទប់សុខភាព (ត)

## ១. សម្ភារៈបិរក្ខារទូទៅ៖




- ❖ តុនិងកៅអីសម្រាប់អ្នកទទួលបន្ទុកប្រចាំការ
- ❖ រនាំងខណ្ឌចែក ឬឡប់ទ្បែ
- ❖ ទូដែលអាចចាក់សោរសម្រាប់ទុកដាក់ឯកសារ
- ❖ នាឡិកាព្យួរជញ្ជាំង
- ❖ កំណត់ត្រាអ្នកប្រើប្រាស់ ចេញ-ចូលបន្ទប់សុខភាព
- ❖ ផ្ទាំងរូបភាពនិងស្លាដែសិស្សនានាទាក់ទងនឹងសុខភាព
- ❖ ធុងសំរាម។

# ៦- សម្ភារៈបរិក្ខារនៅបន្ទប់សុខភាព (ត)

## ២. សម្ភារៈបរិក្ខារសម្រាប់ការពិនិត្យកាយសម្បទា៖



- ❖ សម្ភារៈបរិក្ខារសម្រាប់ការធ្វើតេស្តគំហើញមាន ស្កុត អ៊ីឆាត (E-chart)
- ❖ សម្ភារៈបរិក្ខារសម្រាប់វាស់កម្ពស់ ទម្ងន់មាន បន្ទាត់កែង ខ្សែម៉ែត្រ ស្កុត ជញ្ជីង
- ❖ ឧបករណ៍វាស់សម្ពាធឈាម (Sphygmomanometer) អាចទិញ ឬស្នើសុំពីមន្ទីរពេទ្យឬមណ្ឌលសុខភាពនៅក្បែរ ឬតាមរយៈសប្បុរសជន
- ❖ ផ្ទាំងរូបភាពបកស្រាយពីកម្រិតសម្ពាធឈាម
- ❖ ផ្ទាំងរូបភាពពីការគណនាសន្ទស្សន៍ម៉ាសរាងកាយ (BMI) សម្រាប់កុមារី កុមារ អាយុក្រោម៥ឆ្នាំ និងចន្លោះ៥ទៅ១៩ឆ្នាំ។





# ៦- សម្ភារៈបរិក្ខារនៅបន្ទប់សុខភាព (ត)

## ៣. សម្ភារៈបិរក្ខារសម្រាប់ការអប់រំសុខភាពនិងការប្រឹក្សាសុខភាព៖

- សៀវភៅមុខវិជ្ជាអប់រំសុខភាព និងសៀវភៅពាក់ព័ន្ធនឹងសុខភាពនានាតាមលទ្ធភាព
- ក្តារខៀនព័ត៌មាន ឬក្តារខៀនចល័តក៏អាចប្រើជាផ្ទាំងព័ត៌មានបានដែរ
- ផ្ទាំងរូបភាពពីការអប់រំសុខភាព
- បណ្ណប្រកាសនានាសម្រាប់ផ្សព្វផ្សាយពីការអប់រំសុខភាព
- បណ្ណបង្ហាលេខទំនាក់ទំនងសេវាសុខាភិបាលមូលដ្ឋាននិងសេវាពាក់ព័ន្ធទៅនឹងសុខភាពសាធារណៈដទៃទៀត។

# ៦- សម្ភារៈបរិក្ខារនៅបន្ទប់សុខភាព (ត)

## ៤. សម្ភារៈបរិក្ខារសម្រាប់ការសង្គ្រោះបឋម៖

- គ្រែមួយ (គ្រែធម្មតាដែលអាចប្រើប្រាស់បាន ឬគ្រែពេទ្យរឹតតែប្រសើរ)
- ប្រអប់សង្គ្រោះបឋម
- ក្រណាត់ជូតជើង
- ក្រមា (ទំហំធំនិងតូច)
- ក្រដាសជូត
- ប៉ៅអ៊ី (ដែលអាចបត់បាន)
- សម្ភារៈដទៃទៀតដូចជា ទែម៉ូម៉ែត្រ កន្ត្រៃកាត់ក្រចក ឧបករណ៍ដកបន្លា កន្ត្រៃ ស្បៀរុំ បង់បិតដំបៅ ស្រោមដៃ សំឡី ម៉ាស់ ថង់ប្លាស្ទិក អាល់កុល ទឹកលាងរបួស សំឡីត្បារត្រចៀក សំឡីអនាម័យ។

# ៦- សម្ភារៈបរិក្ខារនៅបន្ទប់សុខភាព (ត)

## ៥. សម្ភារៈអនាម័យ៖

- អំបោស
- ធុងសំរាម
- ក្រដាសជូតដៃ
- សាប៊ូដុំ ឬសាប៊ូទឹកដាក់នៅជិត ឬជាប់កន្លែងលាងសម្អាតដៃ
- ធុងសំរាមដែលមានគម្របសម្រាប់ដាក់សំរាមផ្សេងៗ (បើអាចទៀតគួរមានធុងសម្រាប់សំរាមសើម និងសំរាមស្ងួតដាច់ពីគ្នា)
- សំឡីអនាម័យបម្រុងសម្រាប់សិស្សស្រីប្រើប្រាស់បន្ទាន់។

# ៧- ការសង្គ្រោះបឋម

## ១. គោលបំណង

❖ ជួយសង្គ្រោះជីវិត

❖ បង្ការការឈឺចាប់

❖ ជួយបង្ការពីការរីករាលដាលនៃជំងឺ

❖ ជួយឱ្យឆាប់ជាសះស្បើយ

## ២. វិធីសង្គ្រោះ

❖ របួស ( ការដាច់រលាត់ ការមុត ឈាមច្រមុះ គ្រេច ផ្លោះឬបាក់ឆ្អឹង រលាក )

❖ ជំងឺ ( ឈឺក្បាល ឈឺពោះ )

| លរ | ឈ្មោះបរិក្ខារ | រូបភាព | លរ | ឈ្មោះបរិក្ខារ | រូបភាព |
|---|---|---|---|---|---|
| 1 | ប្រអប់សង្គ្រោះបឋម ( Plastic Box ) |  | 12 | សំឡីត្បារត្រចៀក ( Cotton ear buds ) |  |
| 2 | កន្ត្រៃ ( Scissor ) |  | 13 | សំឡីដុំមូលៗ ( Cotton ball ) |  |
| 3 | ឧបករណ៍ស្ទង់កម្តៅ ( Analog Ter-mometer ) |  | 14 | បង់រុំរបួស ( Elastic Ban-dage ) |  |
| 4 | ដង្កៀប ( Stainless thresher ) |  | 15 | ម៉ាស់ ( Medical Mask ) |  |

# ៨- របៀបពិនិត្យកាយសម្បទា

## ១. ការវាស់កម្ពស់ ថ្លឹងទម្ងន់ និងការគណនាសន្ទស្សន៍ម៉ាសរាងកាយ

- ❖ របៀបវាស់កម្ពស់
- ❖ របៀបថ្លឹងទម្ងន់
- ❖ របៀបគណនាសន្ទស្សន៍ម៉ាស់រាងកាយ

| ល.រ | ឈ្មោះសម្ភារៈ | រូបភាព | ល.រ | ឈ្មោះសម្ភារៈ | រូបភាព |
|---|---|---|---|---|---|
| 1 | ជញ្ជីង (Scale) |  | 7 | ឧបករណ៍វាស់សម្ពាធឈាម (Blood pressure monitor) |  |
| 2 | ម៉ែត្រវាស់កម្ពស់ (Meter for height mea-sure) |  | 8 | ផ្ទាំងរូបភាពសម្រាប់យល់ដឹងពីកម្រិតសម្ពាធឈាម (Blood pressure Chart) |  |
| 3 | បន្ទាត់សម្រាប់វាស់កម្ពស់ (Ruler Mea-surement) |  | 9 | វែកវាស់ភ្នែក (Tool for Vision Test) |  |













## ២. ការវាស់គំហើញ

## ៣. ការវាស់ការស្តាប់

## ៤. ការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ

# ៧- ឯកសារសម្រាប់ប្រើប្រាស់

- ❖ របាយការណ៍ប្រើប្រាស់ចេញ ចូល
- ❖ ទម្រង់តារាងបញ្ចូលទិន្នន័យ
- ❖ រូបភាពបរិក្ខារប្រើប្រាស់

## ៧.១- របាយការណ៍ការប្រើប្រាស់ចេញ-ចូលបន្ទប់សុខភាពប្រចាំខែ




| ល.រ | ម៉ោងចូល | ម៉ោងចេញ | ឈ្មោះ | ភេទ | ថ្នាក់ | រោគសញ្ញា | ទីតាំង | សីតុណ្ហភាព | មូលហេតុ | ការព្យាបាល | សម្ភារៈដែលបានប្រើប្រាស់ | បន្ទាប់ពីពិគ្រោះ | ការចំណាយប្រមាណ(៛) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 8:30 | 8:35 | សុខ ចេនដា | ស | 7A | ឈឺក្បាល | សាលារៀន | 35 | អត់បានហូបបាយ | ប្រេងខ្យល់ | ប្រេងខ្យល់ | ទៅផ្ទះសម្រាក | មិនមាន |
| 2 | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | |

## ៧.២- ទម្រង់តារាងសម្រាប់បញ្ចូលទិន្នន័យការពិនិត្យកាយសម្បទាសិស្ស




## ៧.៣- រូបភាពបរិក្ខារសម្រាប់ប្រើប្រាស់នៅបន្ទប់សុខភាពកម្រិតអនុវិទ្យាល័យ

ក. បរិក្ខារសម្រាប់ការសង្គ្រោះបឋម

| លរ | ឈ្មោះបរិក្ខារ | រូបភាព | លរ | ឈ្មោះបរិក្ខារ | រូបភាព |
|---|---|---|---|---|---|
| 1 | ប្រអប់សង្គ្រោះបឋម (Plastic Box) |  | 12 | សំឡីត្បារត្រចៀក (Cotton ear buds) |  |
| 2 | កន្ត្រៃ (Scissor) |  | 13 | សំឡីដុំមូលៗ (Cotton ball) |  |

# ១០- ឯកសារឌីជីថលសម្រាប់ប្រើប្រាស់

| ល.រ | បរិយាយ | រូបភាព | QR កូដ |
|---|---|---|---|
| 7 | របៀបកត់ត្រាសម្រាប់ការប្រើប្រាស់បន្ទប់សុខភាព ( How to Record Health Room ) |   | |
| គ. ផ្ទាំងរូបភាពសម្រាប់ប្រើប្រាស់វាស់កាយសម្បទា ( Measurement Posters ) | | | |
| 8 | ផ្ទាំងរូបភាពសម្រាប់វាស់គំហើញ ( E-Chart ) |  | |
| 9 | ផ្ទាំងរូបភាពស្តីពីសន្ទស្សន៍ម៉ាសរាងកាយ BMI ( សម្រាប់សិស្សស្រី ) |  | |

# ១១- ការវាយតម្លៃដំណើរការប្រតិបត្តិ

## ឧបករណ៍វាយតម្លៃដំណើរការបន្ទប់សុខភាព

ដោយមន្ត្រីទទួលបន្ទុកការងារសុខភាពសិក្សាគ្រប់កម្រិតថ្នាក់

ឈ្មោះគ្រឹះស្ថានសិក្សា ..........................................................................................

ថ្ងៃកាលបរិច្ឆេទ ..........................................................................................

| ល.រ | ☐ | លក្ខណៈវិនិច្ឆ័យ | ផ្សេងៗ |
|---|---|---|---|
| គណៈកម្មការទទួលបន្ទុកបន្ទប់សុខភាព | | | |
| ១ | ☐ | គណៈកម្មការទទួលបន្ទុកបន្ទប់សុខភាពបានបង្កើតផ្លូវការតាមការណែនាំ មានប្រធាន អនុប្រធាន សមាជិក និងភ្ជាប់ភារកិច្ចតួនាទីច្បាស់លាស់ | |
| ២ | ☐ | គណៈកម្មការទទួលបន្ទុកបន្ទប់សុខភាពបានដំណើរការ ដោយមានការបែងចែកអ្នកទទួលបន្ទុកប្រចាំការរៀងរាល់ថ្ងៃធ្វើការនៅបន្ទប់សុខភាព | |
| ៣ | ☐ | គណៈកម្មការទទួលបន្ទុកបន្ទប់សុខភាពបានប្រជុំជាទៀងទាត់តាមកាលកំណត់ និងប្រជុំជាមួយគណៈកម្មការសុខភាពសិក្សា មានរបាយការណ៍លទ្ធផលកិច្ចប្រជុំ | |
| ៤ | ☐ | គណៈកម្មការទទួលបន្ទុកបន្ទប់សុខភាពមានរៀបចំផែនការសកម្មភាពច្បាស់លាស់សម្រាប់ដំណើរការបន្ទប់សុខភាពពេញមួយឆ្នាំសិក្សា | |

- ពិន្ទុតូចជាងឬស្មើ២០ ក្រោមស្តង់
- ពិន្ទុចន្លោះ២១ទៅ២៧ ស្តង់ដាទាប
- ពិន្ទុចន្លោះ២៨ដល់៣៤ ស្តង់ដាមធ្យម
- ពិន្ទុលើស៣៤ ស្តង់ដាខ្ពស់

# ឃ. បញ្ហាប្រឈមនិងដំណោះស្រាយ

| គ្រឹះស្ថានសិក្សា | ចំនួនសរុប | បន្ទប់សុខភាព ដាច់ដោយឡែក | ជ្រុងណាមួយ ធ្វើជាបន្ទប់សុខភាព | សរុប | % |
|---|---|---|---|---|---|
| មត្តេយ្យសិក្សា ដាច់ដោយឡែក | **380** | 37 | 133 | 170 | 44.7 |
| បឋមសិក្សា | 7,341 | 422 | 1,981 | 2,403 | 32.7 |
| អនុវិទ្យាល័យ | 1,244 | 140 | 423 | 563 | 45.3 |
| វិទ្យាល័យ | 581 | 185 | 220 | 405 | 69.7 |
| **សរុប** | **9,546** | **784** | **2,757** | **3,541** | **37.1** |

- មិនទាន់បានសិក្សាវាយតម្លៃពីស្ថានភាពបន្ទប់សុខភាពតាមសាលារៀន ដែលប្រការនេះចាំបាច់ត្រូវមានការណែនាំអនុវត្តបន្ថែមស្ដីពីស្តង់ដាប្រតិបត្តិអប្បបរមានៅបន្ទប់សុខភាព។

- ដំណើរការប្រតិបត្តិនៅមិនទាន់រលូននិងឯកភាពគ្នា ដែលប្រការនេះចាំបាច់ត្រូវពង្រឹងកិច្ចសហការបន្ថែមពីគ្រប់ភាគីពាក់ព័ន្ធ។



- ធនធាននិងសមត្ថភាពអ្នកអនុវត្តនៅតាមបន្ទប់សុខភាពមិនទាន់សមស្របតាមតម្រូវការ ដែលប្រការទាំងនេះគួរត្រូវពង្រឹងចលនាធនធាននិងសមត្ថភាពអ្នកអនុវត្តផ្ទាល់។



# សូមអរគុណ